# ស្រឡាញ់ ចែកចាយ អញ្ជើញ

## ស្រឡាញ់

យ៉ូហាន ១៣:៣៤–៣៥; ម៉ូសាយ ១៨:២០–២២; គោលលទ្ធិ និងសេចក្តីសញ្ញា ១២:៧–៩; ១២១:៤១–៤២

អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



នៅពេលណាដែលយើងបង្ហាញសេចក្តីស្រឡាញ់ដូចព្រះគ្រីស្ទទៅកាន់អ្នកជិតខាងរបស់យើង នោះយើងផ្សព្វផ្សាយដំណឹងល្អហើយ—សូម្បីតែយើងមិនបាននិយាយពាក្យមួយម៉ាត់ក្តី ។

សេចក្តីស្រឡាញ់សម្រាប់មនុស្សដទៃទៀត គឺជាការបង្ហាញមតិដ៏ពូកែអំពីបទបញ្ញត្តិធំទីពីរ ដែលឲ្យស្រឡាញ់អ្នកជិតខាងយើង ។ វាបង្ហាញពីដំណើរការដែលព្រះវិញ្ញាណបរិសុទ្ធសម្រិតសម្រាំងព្រលឹងរបស់យើង ។ តាមរយៈការបង្ហាញនូវសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទចំពោះមនុស្សផ្សេងទៀត យើងអាចបណ្តាលឲ្យអស់អ្នកដែលឃើញកិច្ចការល្អរបស់យើង « សរសើរតម្កើងដល់ព្រះវរបិតានៃ [ យើង ] រាល់គ្នាដែលគង់នៅស្ថានសួគ៌ » [ ម៉ាថាយ ៥:១៦ ] ។ ( ហ្គែរី អ៊ី ស្ទីវ៉ែនសុន « ស្រឡាញ់ ចែកចាយ អញ្ជើញ » *លីអាហូណា* ខែឧសភា ឆ្នាំ២០២២ ទំព័រ៨៥ )

## ចែកចាយ

នីហ្វៃទី២ ២:៦–៨; ម៉ូសាយ ២៨:១–៣; អាលម៉ា ៣១:៥; គោលលទ្ធិ និងសេចក្តីសញ្ញា ៦០:២

អែលឌើរ ឌៀថើរ អែហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



បើមនុស្សម្នាក់សួរអំពីថ្ងៃចុងសប្តាហ៍របស់បងប្អូន ចូរកុំស្ទាក់ស្ទើរក្នុងការនិយាយអំពីអ្វីដែលបងប្អូនមានបទពិសោធន៍នៅព្រះវិហារ ។ សូមប្រាប់អំពីកុមារតូចៗដែលឈរនៅខាងលើវេទិកាពីមុខក្រុមជំនុំ ហើយច្រៀងចម្រៀងដោយក្លៀវក្លាអំពីរបៀបដែលពួកគេព្យាយាមប្រែក្លាយដូចជាព្រះយេស៊ូវ ។ និយាយអំពីក្រុមយុវវ័យដែលចំណាយពេលជួយដល់មនុស្សជរាដែលនៅផ្ទះ ដើម្បីប្រមូលព័ត៌មានប្រវត្តិផ្ទាល់ខ្លួន ។ . . .

តាមវិធីណាក៏ដោយដែលវាងាយស្រួលសម្រាប់បងប្អូន សូមចែកចាយជាមួយនឹងមនុស្សអំពីមូលហេតុដែលព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់សំខាន់ចំពោះបងប្អូន ។ ( ឌៀថើរ អែហ្វ អុជដូហ្វ « Missionary Work: Sharing What Is in Your Heart » *Liahona* ខែឧសភា ឆ្នាំ២០១៩ ទំព័រ១៧ )

## អញ្ជើញ

យ៉ូហាន ១:៣៥–៤៦; ៤:២៨–៣០, ៣៩–៤១; អាលម៉ា ៥:៦២; មរ៉ូណៃ ១០:៣–៥

អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



មានការអញ្ជើញរាប់រយ ដែលយើងអាចអញ្ជើញទៅអ្នកដទៃទៀតបាន ។ យើងអាចអញ្ជើញមនុស្សផ្សេងទៀតឲ្យ « មក ហើយមើល » ពិធីសាក្រាម៉ង់ សកម្មភាពវួដ វីដេអូតាមអនឡាញ ដែលពន្យល់អំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ « មក ហើយមើល » អាចជាការអញ្ជើញឲ្យអានព្រះគម្ពីរមរមន ឬមកមើលព្រះវិហារបរិសុទ្ធ អំឡុងពេលពិធីសម្ពោធ ពីមុនពិធីឧទ្ទិសឆ្លង ។ ជួនកាល ការអញ្ជើញនោះជាអ្វីមួយដែលយើងអញ្ជើញនៅខាងក្នុង—ជាការអញ្ជើញដល់ខ្លួនយើង ដែលផ្តល់ការយល់ដឹង និងទស្សនវិស័យដល់ខ្លួនយើង អំពីឱកាសទាំងឡាយដែលនៅជុំវិញខ្លួនយើង ដើម្បីធ្វើសកម្មភាពតាម ។ ( ហ្គែរី អ៊ី ស្ទីវ៉ែនសុន « ស្រឡាញ់ ចែកចាយ អញ្ជើញ » *លីអាហូណា* ខែឧសភា ឆ្នាំ២០២២ ទំព័រ៨៦ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_602-1